**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
លេខ ២១២១ អពដ

GENERAL DEPARTMENT OF TAXATION

ថ្ងៃ ... ខែ ... ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០១៨

# សេចក្តីជូនដំណឹង
## ស្តីពី
## កម្រិតអត្រាការប្រាក់ទីផ្សារសម្រាប់ប្រាក់កម្ចី ឆ្នាំ២០១៧

អនុលោមតាមបទប្បញ្ញត្តិ នៃមាត្រា១៨ នៃច្បាប់ស្តីពីសារពើពន្ធ ផ្នែកទី២.៥ និងផ្នែកទី៥.៩ នៃប្រកាសស្តីពីពន្ធលើប្រាក់ចំណេញលេខ១០៥៩ ប្រក.សហវ.ពដ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៣ និង យោងតាមសេចក្តីណែនាំអំពីការកំណត់ចំណាយការប្រាក់របស់សហគ្រាស លេខ១៥៧ អពដ. ចុះថ្ងៃទី ២២ ខែមករា ឆ្នាំ២០១៤ អគ្គនាយកដ្ឋានពន្ធដារបានកំណត់អត្រាការប្រាក់ទីផ្សារសម្រាប់ប្រាក់កម្ចី ដូចខាងក្រោម÷

**១. កម្ចីជាប្រាក់រៀល ១២,១២% ក្នុងមួយឆ្នាំ។** អត្រាការប្រាក់នេះបានមកពីការគណនាមធ្យមភាគ នៃមធ្យមភាគអត្រាការប្រាក់ឲ្យខ្ចីរបស់ធនាគារពាណិជ្ជធំៗ ក្នុងស្រុកចំនួន ០៦ (ប្រាំមួយ) ដោយ ធនាគារពាណិជ្ជធំៗពីរផ្សេងទៀត មិនមានផ្តល់កម្ចីជាប្រាក់រៀល។

**២. កម្ចីជាប្រាក់ដុល្លារអាមេរិក ៩,៣១% ក្នុងមួយឆ្នាំ។** អត្រាការប្រាក់នេះបានមកពីការគណនាមធ្យមភាគ នៃមធ្យមភាគអត្រាការប្រាក់ឲ្យខ្ចីរបស់ធនាគារពាណិជ្ជធំៗ ក្នុងស្រុកចំនួន ០៨ (ប្រាំបី)។

ករណីសហគ្រាសអនុវត្តអត្រាការប្រាក់ទាបជាងអត្រាដែលបានកំណត់ខាងលើ ត្រូវអនុវត្តតាមអត្រាជាក់ស្តែងរបស់សហគ្រាសនោះ។

អាស្រ័យហេតុនេះគ្រប់អង្គភាពពន្ធដារ និងគ្រប់សហគ្រាសជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវអនុវត្តតាមខ្លឹមសារ នៃសេចក្តីជូនដំណឹងនេះ ចំពោះលទ្ធផលសារពើពន្ធសម្រាប់ការិយបរិច្ឆេទឆ្នាំ ២០១៧ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

Collection by VCAT Professional Consultant

**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និង ម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855) 23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh